# ការការពារ និងការព្យាបាលជំងឺគោ

## ១. ការការពារសុខភាពសត្វ

### ១.១ អនាម័យ

**អនាម័យកន្លែងរស់នៅ**

កន្លែងរស់នៅ និងដេកត្រូវសម្អាតឱ្យបានស្អាត និងមិនមានភក់ជ្រាំ ។ ត្រូវកើបលាមកគោឱ្យបានញឹកញាប់ យ៉ាងហោចណាស់ ១-២ដងក្នុងមួយថ្ងៃ ។



*ការសម្អាតលាមក និងសម្រាមក្នុងទ្រុងគោ*

**អនាម័យសត្វ**

ត្រូវលាងសម្អាតខ្លួនគោ ឬក្របីឱ្យបានញឹកញាប់ ជាពិសេសនៅរដូវក្តៅ ។

**អនាម័យចំណីអាហារ និងទឹក**

គោក្របីត្រូវការផឹកទឹកស្អាតច្រើន រៀងរាល់ថ្ងៃ ។ ត្រូវផ្តល់ទឹកឱ្យគោក្របីផឹកមុនពេលផ្តល់ចំណី ហើយយ៉ាងហោចណាស់ឱ្យផឹកយ៉ាងតិចបីដងក្នុងមួយថ្ងៃ ។



មិនត្រូវឱ្យសត្វជាន់ក្នុងស្នូកទឹក និងចំណីនោះទេ ព្រោះវាអាចចម្លងនូវជំងឺ ។

**ទម្លាក់បរាសិត**

បរាសិតចែកជា២ផ្នែកសំខាន់ៗ គឺបរាសិតខាងក្នុង (ព្រូន) និងបរាសិតខាងក្រៅ (អង្កែ តឹកកែ រុយ របោម ជាដើម) ។

កាលណាសត្វមានកើតបរាសិតធ្វើឱ្យការលូតលាស់យឺត ស្គមរីងរៃ និងអាចបណ្តាលឱ្យងាប់បើធ្ងន់ធ្ងរ។

### ១.២. ការការពារ និងទប់ទល់ជំងឺឆ្លង

**ការទប់ស្កាត់ការឆ្លងរាលដាលតាមបែបជីវសុវត្ថិភាព**

បើក្នុងតំបន់មានជម្ងឺឆ្លងកើតឡើងត្រូវបង្ខាំងសត្វមិនឱ្យមានចរាចរណ៍ពីតំបន់មួយទៅតំបន់មួយ និងបង្ខាំងសត្វនៅនឹងកន្លែង។ មិនត្រូវឱ្យសត្វមកពីតំបន់ផ្សេង និងមនុស្សពីក្រៅចូលមកជិតគោក្របីឡើយ ព្រោះអាចចម្លងជំងឺ។

**ការចាក់វ៉ាក់សាំងការពារដើម្បីប្រឆាំងជំងឺ**

នៅពេលដែលបាក់តេរី ឬវីរុសចូលទៅ ក្នុងខ្លួនសត្វនោះសរីរាង្គរបស់សត្វនឹងបង្កើតអង់ទីគ័រដើម្បីទប់ទល់នឹងពួកវា ។

ប្រសិនបើមេរោគជាបាក់តេរីនោះអង់ទីប៊ីយ៉ូទិកនឹងមានប្រសិទ្ធិភាពលើវា ហើយអាចបំផ្លាញ វាបានយ៉ាងរហ័ស ។



តែប្រសិនបើមេរោគជាវីរុស នោះអង់ទីប៊ីយ៉ូទិក មិនមានប្រសិទ្ធិភាពលើវាទេ ហើយអង់ទីប៊ីយ៉ូ ទិកគ្រាន់តែអាចទប់ទល់ជាមួយវីរុសតែប៉ុណ្ណោះ ។

បាក់តេរី ឬវីរុស ជាប្រភេទមេរោគធ្វើការបំបែកខ្លួនបានលឿន ហើយសាយភាយពេញសរីរាង្គទាំងមូល ។ ប្រសិនបើសត្វមិនមានពេលគ្រប់គ្រាន់ដើម្បីបង្កើតអង់ទីគ័រទប់ទល់ជាមួយបាក់តេរី ឬវីរុស នោះសត្វនឹងឈឺ ហើយស្លាប់ ។

ជំងឺឆ្លងសំខាន់ៗ ដែលតែងតែកើតញឹកញាប់ចំពោះគោក្របីគឺជំងឺអុតក្តាម និងសារទឹក ។ ដូច្នេះគោក្របីត្រូវចាក់វ៉ាក់សាំងការពារជំងឺទាំងនេះ ឱ្យបានគ្រប់គ្រាន់ និងទៀងពេលវេលា ។ ជំងឺទាំងនេះភាគច្រើនកើតឡើងនៅរដូវវស្សា ដូច្នេះត្រូវចាក់មុនរដូវវស្សា ១ខែ ដើម្បីទប់ទល់នឹងជំងឺ ។

វ៉ាក់សាំងគឺជាការចាក់បញ្ចូលនូវមេរោគ ដែលមេរោគនោះត្រូវបានបន្ថយសកម្មភាពសម្លាប់ ឬមិនបង្កជំងឺ។ ទម្រង់របស់បាក់តេរី ឬវីរុស ដែលផលិតជាថ្នាំការពារនេះ មិនចង់ឱ្យមានជំងឺទេ តែវាបង្កើតអង់ទីគ័រ ។ អង់ទីគ័រនឹងមាននៅក្នុងខ្លួនសត្វជាច្រើនខែ ហើយអាចទប់ទល់ជាមួយបាក់តេរី ឬវីរុស ដែលធ្វើឲ្យសត្វមិនឈឺ ។

វ៉ាក់សាំងគឺជាថ្នាំចាក់ការពារជំងឺ ។ វាមានសារៈសំខាន់ណាស់ក្នុងការទប់ទល់ជាមួយជំងឺ ។ វ៉ាក់សាំងមួយមុខអាចចាក់ការពារបានតែជម្ងឺមួយមុខប៉ុណ្ណោះ ។ អង់ទីគ័រមានប្រសិទ្ធិភាពក្នុងរយៈពេលខ្លី មិនអាចមានពេញមួយជីវិតនោះទេ ដូច្នេះត្រូវគោរពតាមកម្មវិធីចាក់វ៉ាក់សាំង ។

## ២. ជំងឺឆ្លងរាតត្បាត

### ២.១. ជំងឺឈាមខ្មៅ

ជំងឺឈាមខ្មៅបង្កឡើងដោយបាក់តេរី ឈ្មោះ បាក់ស៊ីឡុស អង់ត្រាក់ស៊ីស (Bacillus anthracis) ។ សត្វអាចស្លាប់ភ្លាមៗ ក្នុរយៈពេលពី ២-៣ម៉ោង។បន្ទាប់ពីស្លាប់ ដងខ្លួនសត្វមានសភាពទន់ មាន ហូរឈាមតាមមាត់ និងរន្ធគូថ ។

សត្វកើតជំងឺឈាមខ្មៅតាមរយៈការចម្លង មេរោគពីបាក់តេរីដែលរស់នៅក្នុងដី ។

នៅពេលដែលមានគោស្លាប់ដោយជំងឺនេះ គោផ្សេងទៀតដែលស៊ីស្មៅក្នុងវាលតែមួយ អាចប្រឈមនឹងការឆ្លងជំងឺនេះដែរ ។



ភ្នាសស្តើងគ្របកភ្នែកមានពណ៌ ដូចទឹកដោះគោ



ខ័ណ្ណាលឿង

ក្នុងករណីមិនស្រួចស្រាវ សត្វអាចចុះខ្សោយខ្លាំង មានកម្តៅរហូតដល់ ៤១.៥ អង្សាសេ ពិបាកដកដង្ហើម មានឈាមក្នុងទឹកនោម ទឹកដោះ និងលាមក សត្វមិនអាចបញ្ឈោខ្លួនបាន និងសន្លប់ ។

**ការព្យាបាល**

ប្រសិនបើសត្វចាប់ផ្តើមឈឺ ត្រូវតែធ្វើការព្យាបាលភ្លាមៗ ដោយប្រើពពួកអង់ទីប៊ីយ៉ូទិក ។

**ការចាក់វ៉ាក់សាំង**

ការចាក់វ៉ាក់សាំងការពារជំងឺឈាមខ្មៅ ជាវិធានការមួយដ៏មានប្រសិទ្ធភាព ។ ក្នុងមួយឆ្នាំត្រូវចាក់វ៉ាក់សាំងការពារជំងឺនេះម្តង ដោយចាក់មុនរដូវភ្លៀងធ្លាក់។

### ២.២. ជំងឺបូសខ្យល់

ជំងឺនេះបង្កឡើងដោយបាក់តេរីឈ្មោះ ក្លូស្ទ្រីដ្យូម



ត្រូវពិនិត្យលើការហើម ទន់ឬរឹង ឈឺចាប់ឬមិនឈឺចាប់ ក្តៅឬត្រជាក់



បូសនៅកន្សោមដោះដោយក្តៅខាំ បានបែកដោយខ្លួនឯង

ស្វូវ៉ី (Clostridium Chauvei) ។ ជំងឺនេះ ច្រើនកើតឡើងលើគោដែលមានអាយុពី ៦-២៤ខែ ។

ជំងឺបូសខ្យល់អាចឱ្យសត្វស្លាប់រយៈពេលពី ១២-២៤ម៉ោង ដោយមិនបញ្ចេញរោគសញ្ញាអ្វីទាំងអស់ ។

ជាទូទៅគេឃើញគោស្លាប់ ដោយពុំមានឃើញអាការៈឈឺឡើយ ហើយក៏មិនចម្លងពីសត្វមួយទៅសត្វមួយទៀតដែរ លុះត្រាតែសត្វដែលពុំមានជំងឺទៅស៊ីស្មៅ ខ្ញីកៀកនឹងដីដែលមានមេរោគ ទើបអាចឈឺបាន ។

ករណីមិនស្រួចស្រាវ សត្វមិនចង់ដើរ ដោយសារឈឺជើង ។ នៅសាច់ដុំត្រគៀក ស្មា ឬក មានហើម និងឮសូរសម្លេងខ្យល់ ។ ពេលចាប់ផ្តើមដំបូង កន្លែងហើមមានទំហំតូច ក្តៅ និងឈឺចាប់ ខ្លាំង ។ ដោយសារជំងឺនេះវិវត្តន៍លឿន ធ្វើឱ្យកន្លែងហើមនេះរីកធំឡើង ហើយពេលស្ទាបឮសូរសម្លេង ប្រិបៗ ។

**ការព្យាបាល**

ពេលដែលដឹងថាសត្វឈឺត្រូវចាក់ប៉េនីស៊ីលីន ឬអាម៉ុក ស៊ីលីន ដោយចាក់សាច់ដុំ និងចាក់នៅជុំវិញ កន្លែងដែលហើមក្នុងសាច់ដុំ ។

**ការចាក់វ៉ាក់សាំង**

វ៉ាក់សាំងដែលចាក់ទៅមានប្រសិទ្ធភាព គឺវ៉ាក់សាំង ៧មុខ ដែលអាចប្រឆាំងបានគ្រប់ក្លូស្ទ្រីដ្យូម ។

**ការចាក់វ៉ាក់សាំង ៖**

- លើកទី ១ ពេលដែលកូនគោអាយុ ២ខែ
- លើកទី ២ ធ្វើឡើង ១ខែ ក្រោយលើកទី ១
- លើកទី ៣ ធ្វើឡើង ១ឆ្នាំ ក្រោយលើកទី ២



*សួតគោពុំមានជំងឺ*



*សួតគោមានជំងឺ*



*ពេលរលាកសួតចាប់ផ្តើម មានសំបោរហូរខ្លាំង*



*សំបោរក្លាយជាខ្ទុះ ពេលមានខ្ទុះនៅសួត ឬទងសួត*

- ចាក់រំលឹករៀងរាល់ ៥ឆ្នាំម្តង ។

**២.៣. ជំងឺសារទឹក**

ជំងឺនេះបង្កឡើងដោយបាក់តេរីឈ្មោះ ប៉ាស្ទ័ររ៉ែលឡា មុលតូស៊ីដា ប្រភេទ បេ (Pasteurella Multocida Type B)។ បាក់តេរីប្រភេទនេះបង្កឡើងតែនៅលើសត្វ